**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ១៣៦ កសណ.រគម

ថ្ងៃ សុក្រ ១៤រោច ខែ ផល្គុន ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## ការតម្រូវឱ្យដាក់ពាក្យស្នើសុំថ្មី ឬបន្តអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធអនឡាញ ដើម្បីចូលរួមកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ ក្នុងសហគមន៍

អង្គភាពច្រកចេញ-ចូលតែមួយនៃក្រសួងទេសចរណ៍ មានកិត្តិយសសូមជម្រាបជូនដល់ម្ចាស់ ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ទាំងអស់មេត្តាជ្រាបថា អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាល និងសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ អង្គភាពច្រកចេញ-ចូលតែមួយនៃក្រសួងទេសចរណ៍ តម្រូវឱ្យដាក់ពាក្យស្នើសុំថ្មី ឬបន្តអាជ្ញាបណ្ណទេសចរណ៍គ្រប់ប្រភេទ ត្រូវធ្វើតាមប្រព័ន្ធអនឡាញ (www.cambodiatourismindustry.com) គិតចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់មានការជូនដំណឹងសារជាថ្មី ដើម្បីចូលរួមកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ ក្នុងសហគមន៍។ លោកអ្នកដោយគ្រាន់តែចូលទៅកាន់គេហទំព័រ www.cambodiatourismindustry.com ឬស្កេន QR Code ដើម្បីធ្វើការស្នើសុំថ្មី ឬបន្តអាជ្ញាបណ្ណទេសចរណ៍។

ទទួលបានសេចក្តីជូនដំណឹងនេះ សូម លោក លោកស្រីម្ចាស់ ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ទាំងអស់ចូលរួមអនុវត្តឱ្យបានខ្ជាប់ខ្ជួនទូវស្មារតីសេចក្តីជូនដំណឹងនេះ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ពិសេសការរីករាលដាលក្នុងសហគមន៍។ សម្រាប់ព័ត៌មានបន្ថែមលោកអ្នកអាចទំនាក់ទំនងតាមរយៈលេខទូរសព្ទ៖ ០៨៩ ៧៦ ៧៦ ៦៤- ០៩២ ៧៧ ៩៨ ៣៣។

**ក្រសួងទេសចរណ៍**

ក្រសួង ទេសចរណ៍

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ក្រសួងសុខាភិបាល
  "ដើម្បីជូនជ្រាប"
- រដ្ឋបាលរាជធានី-ខេត្ត
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត
- គ្រប់សមាគមក្នុងឧស្សាហកម្មទេសចរណ៍
  "ដើម្បីផ្សព្វផ្សាយ"
- ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មសេវាកម្មទេសចរណ៍
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

វិមានលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org